ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៥ អជណ.កបម

# សេចក្តីថ្លែងហេតុ
# អំពី
# សេចក្តីព្រាងច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន) និងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន ត្រូវបានចុះហត្ថលេខានៅរដ្ឋធានីណៃពិដោនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នាថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ ដោយរដ្ឋមន្ត្រីពាណិជ្ជកម្មនៃប្រទេសជាសមាជិកអាស៊ាន និងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន។ កិច្ចព្រមព្រៀងនេះអាចអនុវត្តទៅបាន លុះត្រាតែប្រទេសហត្ថលេខីបានបំពេញនីតិវិធីក្នុងស្រុករបស់ខ្លួនចប់សព្វគ្រប់ ហើយធ្វើការជូនដំណឹងទៅអគ្គលេខាធិការអាស៊ានជាមុន។ មកទល់ពេលនេះ មានប្រទេសអាស៊ានចំនួន៨ និងក្រុងហុងកុង ដែលបានផ្តល់សច្ចាប័នដល់កិច្ចព្រមព្រៀងនេះ ដោយនៅសល់តែប្រទេសកម្ពុជានិងព្រុយណេប៉ុណ្ណោះ។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិនមានគោលបំណង (១)ធ្វើសេរីភាវូបនីយកម្មនិងសម្រួលពាណិជ្ជកម្មទំនិញរវាងភាគីនៃកិច្ចព្រមព្រៀង តាមរយៈការលុបបំបាត់ពន្ធគយនិងរបាំងមិនមែនពន្ធគយ (២)ធ្វើសេរីភាវូបនីយកម្មនិងសម្រួលពាណិជ្ជកម្មសេវាកម្មឱ្យបានច្រើនវិស័យ (៣)ជំរុញនិងលើកកម្ពស់កាលានុវត្តភាពវិនិយោគ (៤)ពង្រឹងការធ្វើពិពិធកម្ម លើកកម្ពស់ការតភ្ជាប់ពាណិជ្ជកម្ម វិនិយោគ និងសេដ្ឋកិច្ចរវាងភាគីទាំងអស់ និង(៥)ផ្តល់ប្រព្រឹត្តិកម្មពិសេសដល់សមាជិកអាស៊ានជាពិសេសសមាជិកអាស៊ានចូលថ្មី ដើម្បីសម្រួលដល់ការធ្វើសមាហរណកម្មសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធិភាព។

កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិននេះ មានចំនួន១៤ជំពូក ដែលមានខ្លឹមសារសំខាន់ ដូចតទៅ៖

- ជំពូកទី១ : ការបង្កើតតំបន់ពាណិជ្ជកម្មសេរី គោលបំណង និយមន័យទូទៅ និងការបកស្រាយ
- ជំពូកទី២ : ពាណិជ្ជកម្មទំនិញ
- ជំពូកទី៣ : វិធានដើមកំណើត
- ជំពូកទី៤ : នីតិវិធីគយនិងកិច្ចសម្រួលពាណិជ្ជកម្ម
- ជំពូកទី៥ : វិធានការអនាម័យនិងភូតគាមអនាម័យ
- ជំពូកទី៦ : ស្តង់ដា បទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីវាយតម្លៃអនុលោមភាព
- ជំពូកទី៧ : ឧបាស្រ័យពាណិជ្ជកម្ម

- ជំពូកទី៨ : ពាណិជ្ជកម្មសេវាកម្ម
- ជំពូកទី៩ : កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស
- ជំពូកទី១០ : កម្មសិទ្ធិបញ្ញា
- ជំពូកទី១១ : បទប្បញ្ញត្តិទូទៅនិងការលើកលែង
- ជំពូកទី១២ : បទប្បញ្ញត្តិរៀបចំអង្គភាព
- ជំពូកទី១៣ : ការពិគ្រោះយោបល់និងការដោះស្រាយវិវាទ
- ជំពូកទី១៤ : អវសានបញ្ញត្តិ។

ព្រះរាជាណាចក្រកម្ពុជានឹងទទួលបានអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងនេះ ដូចខាងក្រោម៖

- ធ្វើឱ្យពាណិជ្ជកម្មរវាងប្រទេសអាស៊ាននិងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន មានភាពប្រសើរឡើងដើម្បីឆ្លើយតបទៅនឹងភាពរីកចម្រើននៃសេដ្ឋកិច្ចសកល
- ធ្វើឱ្យកាន់តែស៊ីជម្រៅនូវការតភ្ជាប់សេដ្ឋកិច្ចរវាងប្រទេសអាស៊ាននិងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន តាមរយៈការបន្តធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មទំនិញ ពាណិជ្ជកម្មសេវាកម្ម និងការធ្វើឱ្យប្រសើរឡើងនូវនីតិវិធីគយនិងវិធានការនានា
- លើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេសរវាងប្រទេសអាស៊ាននិងហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន
- រួមចំណែកដ៏សំខាន់ក្នុងការសម្រួលដល់ពាណិជ្ជកម្មនិងវិនិយោគឆ្លងដែន ព្រមទាំងកាត់បន្ថយនូវរបាំងចូលទីផ្សារដើម្បីជំរុញដល់ភាពងាយស្រួលដល់សហគ្រាសធុនតូចនិងមធ្យម។

សេចក្តីព្រាងច្បាប់ពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិន ត្រូវបានគណៈរដ្ឋមន្ត្រីសម្រេចយល់ព្រមក្នុងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីនាថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០ ដើម្បីបញ្ជូនទៅសុំការពិនិត្យនិងអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិដែលរួមមាន ២មាត្រា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមរដ្ឋសភាមេត្តាពិនិត្យនិងអនុម័តសេចក្តីព្រាងច្បាប់ពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ហុងកុងនៃសាធារណរដ្ឋប្រជាមានិតចិនដោយក្តីអនុគ្រោះ។

ថ្ងៃសុក្រ ១០ រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**